# ១- រឿងមហាឫសីប្រោសខ្លា

មាននិទានមួយដំណាលថា : មានខ្លាទោល ១ ទៅដេកលើរូងពស់ ១លូនចេញមកចឹកខ្លានោះស្លាប់នៅមាត់រូង ។ ថ្ងៃនោះជួនជាមហាឫសីមួយអង្គនិមន្តគោចរ ទៅឃើញខ្លានោះស្លាប់ ក៏មេត្តាប្រោសខ្លានោះឲ្យរស់ឡើងវិញ ។ ខ្លារស់ដឹងខ្លួនហើយនិយាយថា "អញកំពុងតែដេកលក់ជាសុខសប្បាយក្នុងព្រៃជាលំនៅរបស់អញ ម្តេចឡើយក៏ព្រះស្តែងហ៊ានមកធ្វើឲ្យអញភ្ញាក់ ម្ល៉េះហើយអញខាំព្រះស្តែង ស៊ីពុំលែងឡើយ" ។ មហាឫសីឆ្លើយថា "ព្រះស្តែងដេកលើរូងពស់ ១ ចឹកស្លាប់ អញប្រោស ព្រះស្តែងឲ្យរស់ឡើងវិញ គួរតែព្រះស្តែងសងគុណអញ ម្តេចឡើយក៏ព្រះស្តែងគិតខាំអញវិញ" ។ មហាឫសីនិងខ្លាប្រកែកជជែកគ្នាមិនអស់ មិនហើយ ទើបនាំទៅប្តឹងចចក ថ្លែងប្រាប់តាមដំណើររៀងខ្លួន ។ ចចកជញ្ជឹងគិតថា "អញនៅក្នុងព្រៃសព្វថ្ងៃនេះពឹងពាក់អានុភាពខ្លា បើអញកាត់ក្តីនេះឲ្យខ្លាចាញ់ សមអញនឹងពឹងពាក់ខ្លានៅនាព្រៃនេះពុំបានឡើយ" ។ ចចកគិតដូច្នេះហើយ ក៏កាត់ក្តីឲ្យខ្លាស៊ីមហាឫសី ។ ឯចចកកាត់ក្តីយ៉ាងនេះហៅថា ឆន្ទាគតិ ។

មហាឫសីមិនសុខចិត្ត ប្រកែកគ្នាទៅវិញទៅមក ហើយនាំខ្លាទៅប្តឹងគោ ថ្លែងប្រាប់តាមដំណើររៀងខ្លួនដូចមុន ។ គោគិតថា "បើអញកាត់ក្តីឲ្យខ្លាចាញ់ សមខ្លានេះស្អប់អញ វានឹងខាំអញមិនខានឡើយ" ។ ទើបគោកាត់ក្តីឲ្យខ្លាស៊ីមហាឫសី ។ គោកាត់ក្តីយ៉ាងនេះហៅថា ភយាគតិ ។

មហាឫសីមិនសុខចិត្តនាំខ្លាទៅប្តឹងស្វា។ គិតថា "កាលមុនមានបុរសម្នាក់ធ្លាក់ទៅក្នុងអណ្តូង ឪពុកអញជួយសង្គ្រោះយោងឡើងមកលើមាត់អណ្តូងបាន មានខ្លាមួយគិតមកស៊ីបុរសនោះ ឪពុកអញនាំបុរសនោះ ឲ្យឡើងទៅលើដើមឈើ បានរួចពីភ័យ បុរសនោះបែរជាចិត្តអាក្រក់សម្លាប់ឪពុកអញវិញ" ។ ស្វាគិតដូច្នេះហើយ ទើបកាត់ក្តីឲ្យខ្លាស៊ីមហាឫសី ។ ស្វាកាត់ក្តីយ៉ាងនេះ ហៅថា ទោសាគតិ ។

មហាឫសីមិនសុខចិត្តនាំខ្លាប្តឹងត្មាត ។ គិតថា "សព្វថ្ងៃនេះអញបានរំពាសំណល់អំពីខ្លាជាអាហារចំណីប្រក្រតី មិនដែលដាច់ឡើយ បើអញកាត់ក្តីនេះឲ្យខ្លាចាញ់ មុខជាខ្លាខឹងនឹងអញ ម្តេចឡើយអញនិងបានស៊ីរំពាខ្លានេះទៀត" ។ ត្មាតគិតដូច្នេះហើយ ក៏កាត់ក្តីឲ្យខ្លាស៊ីមហាឫសី ។ ត្មាតកាត់ក្តីយ៉ាងនេះហៅថាលោភាគតិ ។

មហាឫសីមិនសុខចិត្តនាំខ្លាទៅប្តឹងទេព្រក្សៗគិតថា "មនុស្សទាំងពួងដើរ ព្រៃអាស្រ័យដោយម្លប់ឈើផងទាំងឡាយ ចេះតែកាច់មែក ហែកសន្លឹក ស្ទោះសម្បក ឆ្លកកាត់ដើម" ។ ទេព្រក្សគិតដូច្នេះហើយក៏កាត់ក្តីឲ្យខ្លាស៊ីមហាឫសី ។ ទេព្រក្សកាត់ក្តីយ៉ាងនេះហៅថាមោហាគតិ មិនទៀងត្រង់ឡើយ ។

មហាឫសីមិនសុខចិត្តនាំខ្លាទៅប្តឹងទន្សាយប្រាប់ថា "ខ្លានោះដេកលើរន្ធពស់វែក ១ ចេញមកចឹកស្លាប់ អាត្មាសូត្រមន្តបោសពិសពស់ឲ្យខ្លារស់ឡើងវិញ ។ ដោយគិតឃើញថាខ្លានេះនឹងតបគុណអាត្មា, ឥឡូវនេះម្តេចខ្លាក៏ប្រាថ្នាស៊ីអាត្មាវិញ? តាមតែពិចារណាឲ្យអាត្មាចុះ" ។ ឯខ្លាប្តឹងថា "ខ្ញុំកំពុងតែដេកលក់ជាសុខសប្បាយក្នុងព្រៃ ស្រាប់តែព្រះស្តែងឫសីនេះធ្វើឲ្យខ្ញុំភ្ញាក់ ហេតុនេះត្រូវខ្ញុំសុំស៊ីព្រះស្តែងឫសីនេះ ។ ពុំសុខចិត្តនាំខ្ញុំទៅប្តឹងចចក ។ កាត់ឲ្យខ្ញុំស៊ីឫសីនេះ ។ មិនសុខចិត្តនាំខ្ញុំទៅប្តឹងគោ ។ កាត់ឲ្យខ្ញុំស៊ីឫសីនេះ។ មិនសុខចិត្តនាំខ្ញុំទៅប្តឹងស្វា។ កាត់ឲ្យខ្ញុំស៊ីឫសីនេះ។ មិនសុខចិត្តនាំខ្ញុំទៅប្តឹងត្មាត។ កាត់ឲ្យខ្ញុំស៊ីឫសីនេះ។ មិនសុខចិត្តនាំខ្ញុំទៅប្តឹងទេព្រក្ស ។ កាត់ឲ្យខ្ញុំស៊ីឫសីនេះ ។ មិនសុខចិត្តនាំខ្ញុំមកប្តឹងលោក តាមតែលោកពិចារណាឲ្យខ្ញុំចុះ" ។

ទន្សាយស្តាប់ពាក្យមហាឫសី និងពាក្យខ្លាហើយ ក៏ពិចារណាដោយប្រាជ្ញាឈ្លាសវៃ ឈ្វេងយល់អាថ៌សេចក្តីហើយប្រាប់ថា ″បើដូច្នោះចូរមហាឫសី និងបងខ្លានាំគ្នាទៅដល់ទីដែលកើតហេតុនោះហើយឲ្យបងខ្លាដេកលក់ជាសុខដូចពីដើមចុះ គឺឲ្យមហាឫសីជូនទៅដល់កន្លែងដែលខ្លាដេកនោះឲ្យអញបានយល់ហើយនិងពិចារណាដោយប្រការនោះ ″ ។ ទើបមហាឫសី និងខ្លាបបួលគ្នាទៅ នាំទាំងទន្សាយទៅផង ។ លុះទៅដល់កន្លែងនោះហើយ ខ្លាក៏ប្រះដេកនៅទីដដែលនោះ យូរបន្តិចពស់វែកចេញមកចឹកខ្លាស្លាប់នៅមាត់រន្ធនោះឯង ។ កាលបើខ្លានោះស្លាប់ហើយ ទន្សាយប្រាប់មហាឫសីថា ″សូមលោកមើលខ្លានោះចុះ ហេតុតែឥតធម៌វង្វេងភ្លេចគុណគេ ឥឡូវពុំរំលងនិងវេរាកម្មឡើយ, តាំងពីពេលនេះទៅមុខ លោកកុំធ្វើគុណនឹងខ្លាឲ្យសោះ ″ ឯទន្សាយកាត់ក្តីយ៉ាងនេះហៅថាសុគតិគមនំ (ដំណើរល្អ) គឺសុចរិត យុត្តិធម៌ហោង ។